# II. ទីស្តីការគណៈរដ្ឋមន្ត្រី

## ១. អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤

### អនុក្រឹត្យលេខ ៧៧ អនក្រ
### ស្តីពីភារកិច្ច និង រចនាសម្ព័ន្ធទូទៅនៃ
### កងរាជអាវុធហត្ថ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០២ កក្កដា ១៩៩៣ ស្តីពីការតែងតាំងសហអគ្គមេបញ្ជាការនៃកងកំលាំងប្រដាប់អាវុធជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃ កងទ័ពជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ចនិងរចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ
- បានឃើញយោបល់របស់ទីប្រឹក្សាខាងកិច្ចការពារជាតិនិងក្រុមប្រឹក្សាអ្នកច្បាប់អមនាយករដ្ឋមន្ត្រី

### សំរេច

**មាត្រា ១ :** កងរាជអាវុធហត្ថដែលគ្រប់គ្រងដោយអគ្គសេនាធិការ កងយោធពលខេមរភូមិន្ទនោះ ត្រូវឋិតនៅក្រោមបញ្ជាផ្ទាល់ របស់នាយករដ្ឋមន្ត្រី ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីជាអ្នកកំណត់ក្របខ័ណ្ឌសកម្មភាពទូទៅ ។ សហរដ្ឋមន្ត្រីក្រសួងការពារជាតិជាអ្នកទទួលខុសត្រូវលើផ្នែករដ្ឋបាលទូទៅ និង ជាអ្នកផ្តល់សំភារៈ និង ថវិកាសំរាប់ផ្គត់ផ្គង់កងរាជអាវុធហត្ថ ។ អគ្គសេនាធិការកងយោធពលខេមរភូមិន្ទមានភារៈគ្រប់គ្រងសំដៅហ្វឹកហ្វឺន

កសាងរៀបចំកងរាជអាវុធហត្ថអោយរីកចំរើន ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរ៉ាប់រង តួនាទី និង ភារកិច្ចរបស់ខ្លួន ។

**មាត្រា ៣ :** កងរាជអាវុធហត្ថជាផ្នែកមួយរបស់កងយោធពលខេមរភូមិន្ទ ដែលមានស្វ័យភាពក្នុងកិច្ច អនុវត្តច្បាប់កងរាជអាវុធហត្ថមានសកម្មភាពផ្នែកប៉ូលីសដែលមានឧបនិស្ស័យជាអន្តរក្រសួង ។ សមត្ថកិច្ចកងរាជអាវុធហត្ថត្រូវអនុវត្តពេញផ្ទៃប្រទេសទាំងមូល ទៅលើពលរដ្ឋស៊ីវិលព្រមទាំងទៅលើយោធាក្នុងជួរកងទ័ពផង ។

**មាត្រា ៤ :** កងរាជអាវុធហត្ថមានភារកិច្ច :

### ក.រ៉ាប់រងសកម្មភាពខាងប៉ូលីសរដ្ឋបាល :

-រក្សាសុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈ

-រ៉ាប់រងអោយមានការគោរពច្បាប់ និង បទបញ្ជាទាំងឡាយ

-ផ្តល់ព័ត៌មាន និង ជួយសង្គ្រោះពលរដ្ឋស៊ីវិល

ក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជារបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច ។

### ខ.រ៉ាប់រងសកម្មភាពខាងប៉ូលីសតុលាការ :

-ពិនិត្យកត់ត្រានូវឧក្រិដ្ឋកម្ម និង ទោសកម្ម

-ធ្វើកំណត់ហេតុអំពីបទល្មើស

-ប្រមូលផ្តុំភស្តុតាងផ្សេងៗ

-ស្រាវជ្រាវរាវរកអ្នកប្រព្រឹត្តបទល្មើស ដើម្បីបញ្ជូនខ្លួនទៅតុលាការតាមដីការតុលាការ

-ទទួលបន្ទុកអនុវត្តតាមដីកាផ្ទេរអំណាចពីចៅក្រមស៊ើបសួរ

ក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អង្គការ អយ្យការ និង អាជ្ញាធរតុលាការមានសមត្ថកិច្ច ។

### គ.បំពេញបេសកកម្មដែលមានលក្ខណៈពិសេសខាងយោធា :

-ទទួលបន្ទុករក្សាសុវត្ថិភាព និង បំពេញតួនាទីជាកងកិត្តិយសជាប្រយោជន៍ដល់ស្ថាប័នរាជរដ្ឋាភិបាល និង អាជ្ញាធរជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៤

# អនុក្រឹត្យលេខ ១៤៧ អនក្រ
# ស្តីពីការជូន មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ

-តាមសំណើប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

## សំរេច

**មាត្រា ១ :** ត្រូវបានប្រល់មេដាយស្ថាបនាជាតិ ជូនចំពោះសប្បុរសជនដែលមានសទ្ធាជ្រះថ្លាបានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួន ចូលរួមក្នុងការកែលំអសោភ័ណភាពរាជធានីភ្នំពេញដូចមានរាយនាមខាងក្រោមនេះ ÷

ក-មេដាយស្ថាបនាជាតិថ្នាក់លេខ ១ :

១-លោកស្រី MUCHAKUTOKI ប្រធានសាខាអង្គការជំនួយ សូតូស៊ូ ជប៉ុន ឧបត្ថម្ភប្រាក់ ៩៤.៥១២ ដុល្លារអាមេរិក

២-លោក **ថេង ប៊ុនម៉ា ក្រុមហ៊ុន ថៃប៊ុនរ៉ុង** ឧបត្ថម្ភប្រាក់ ៥០.០០០ ដុល្លារអាមេរិក

៣-ក្រុមហ៊ុន MOTOR WORKS ឧបត្ថម្ភរថយន្តពន្លត់អគ្គីភ័យមួយគ្រឿង តំលៃ ២៨.០០០ ដុល្លារអាមេរិក

៤-ក្រុមហ៊ុន សណ្ឋាគារ ហូលីដេយ៍ ឧបត្ថម្ភប្រាក់ ២០.០០០ ដុល្លារអាមេរិក

៥-លោក **សុខ គង់** ក្រុមហ៊ុន សូគីម៉ិច ឧបត្ថម្ភប្រាក់ ២០.០០០ ដុល្លារអាមេរិក

៦-លោកស្រី **ឈុន លាង** ក្រុមហ៊ុនវឌ្ឍនៈ ឧបត្ថម្ភប្រាក់ ២០.០០០ ដុល្លារអាមេរិក

៧_ក្រុមហ៊ុន សណ្ឋាគារអភិវឌ្ឍន៍ទីក្រុង ឧបត្ថម្ភប្រាក់ ១៥.២៨០ ដុល្លារអាមេរិក

៨_លោកស្រី **លឹម ស៊ីណា** ប្រធានសហគ្រាសផលិតទឹកកក ឧបត្ថម្ភប្រាក់ ១០.០០០ ដុល្លារអាមេរិក

ខ_មេដាយស្ថាបនាជាតិថ្នាក់លេខ ៣ :

១_លោក **ឫទ្ធី ហេង** ឧបត្ថម្ភប្រាក់ចំនួន ១.០៥០ ដុល្លារអាមេរិក

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៤*

# អនុក្រឹត្យលេខ ១៤៨ អនក្រ
# ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

_បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ

_បានឃើញគុណបំណាច់របស់សប្បុរសជនក្នុងការរួមចំណែកជួយសង្គ្រោះភាពរាំងស្ងួតរបស់ប្រជារាស្ត្រ